**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខ:០២០/០៩ រប.កកចយ

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ សីហា ឆ្នាំ ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ សីហា ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បាន ដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាន នូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

### ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**ក. ការងាររដ្ឋបាល**

- ផ្ញើលិខិតលេខ ០៥៤/០៩ លស.កកចយ ចុះថ្ងៃទី០៣ ខែសីហាឆ្នាំ២០០៩ ផ្ញើជូនស្ថាប័នពាក់ព័ន្ធ និង វិស័យតុលាការ ស្តីពីសំណើរសុំលើកពេលនៃកិច្ចប្រជុំ ស្តីពីការដោះស្រាយបញ្ហាប្រឈម ក្នុងវិស័យតុលាការ នៅថ្ងៃពុធ ទី០៥ ខែសីហា ឆ្នាំ២០០៩ ទៅថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ ២០០៩ វេលាម៉ោង ៩០:០០ ព្រឹក ។

- ផ្ញើលិខិតលេខ០៥៥/០៩ លស.កកចយ ចុះថ្ងៃទី០៦ ខែសីហាឆ្នាំ២០០៩ ជូនឯកឧត្តម អគ្គលេខាធិការរងរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្រ្តី ស្តីពីសំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវ ម្រាប់ថ្នាក់ដឹកនាំ និង មន្រ្តីក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បីចូលរួមសិក្ខាសាលាស្តីពីបណ្តាញទំនាក់ទំនងក្រុមការងារ បច្ចេកទេសចម្រុះ (Technical Working Group (TWGs) Networking Retreat) នៅខេត្ត សៀមរាប ។

- ផ្ញើលិខិតលេខ ០៥៦/០៩ GS.CLGR ផ្ញើលិខិតថ្លែងអំណរគុណជូន ឯកឧត្តម Jung chung Subបនៃសាលារណៈរដ្ឋកូរ៉េខាងត្បូង ។

- ផ្ញើលិខិតលេខ ០៥៧/០៩ លស.កកចយ សំណើសុំចាត់តាំងមន្រ្តីមួយរូប ទៅសិក្សាថ្នាក់អនុបណ្ឌិតច្បាប់ពាណិជ្ជកម្ម និងសេដ្ឋកិច្ច នៅប្រទេសជប៉ុន ។

- ផ្ញើលិខិតលេខ ០៥៨/០៩ ពប.កកចយ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ផ្ញើព្រឹត្តិប័ត្រលេខ ០២ របស់ អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ទៅអភិបាលគ្រប់រាជធានី-ខេត្ត សាលាដំបូង រាជធានី-ខេត្ត គ្រប់ក្រសួងស្ថាប័ន ស្ថានទូត អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានា។

- ផ្ញើលិខិតលេខ ០៥៩/០៩ លស.កកចយ ផ្ញើជូនឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សំណើរសុំយោបល់ រៀបចំប្រជុំក្រុមប្រឹក្សា នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០ នាទីព្រឹក។

- ផ្ញើលិខិតលេខ ០៦០/០៩ លស.កកចយ សំណើសុំជំនួយ (សហប្រត្តិបត្តិការដើម្បីជួយរៀបចំ )។

- ផ្ញើលិខិតលេខ០៦២/០៩ លស.កកចយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ជូនឯកឧត្តម អគ្គលេខាធិការរងរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវ សម្រាប់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បីចុះទៅធ្វើសិក្ខាសាលាស្តីពីការពង្រឹង ប្រសិទ្ធិភាពនៃភាពជាដៃគូ នៅខេត្តសៀមរាប។

- ផ្ញើលិខិតលេខ ០៦៣/០៩ លស.កកចយ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ជូនឯកឧត្តម អគ្គលេខាធិការ រងរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវ សម្រាប់ថ្នាក់ដឹកនាំ ប្រធានផ្នែក អនុប្រធានផ្នែក និងមន្រ្តីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចុះទៅធ្វើផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន នៅខេត្តព្រះសីហនុ ។

- ផ្ញើលិខិតលេខ០៦៤/០៩ លស.កកចយ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ជូនឯកឧត្តម អគ្គលេខាធិការ រងរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចុះទៅទំនាក់ទំនងជាមួយសាលាខេត្ត ដើម្បីចុះទៅចូលរួមសិក្ខសាលា ស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្តនិងសង្គមស៊ីវិល លើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការ នៅតាមបណ្តាខេត្តដើម្បីពិចារណារកវិធីសាស្ត្រដែលល្អ ប្រសើរសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តបន្ទាយមានជ័យ ។

-ផ្ញើលិខិតលេខ ០៦៥/០៩ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំសិក្ខាសាលផ្តោតទៅលើកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅ សាលាខេត្តចំនួនបួនគឺ: ខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ធំ និងព្រៃវែង។

- បានទទួលលិខិតលេខ៣២៧ រប.ឧ.២០០៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ពីសាលាឧទ្ធរណ៍ អញ្ជើញចូលរួមជាកិត្តិយសនៅក្នុងសិក្ខាសាលាស្តីអំពី វិធីសាស្ត្រតាក់តែងសេចក្តីសម្រេចតុលាការ នាថ្ងៃទី ៥-៦-៧ ខែសីហា ឆ្នាំ២០០៩ ។

- បានទទួលលិខិតលេខ ៣២៨ លអជ.រប. ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញឯកឧត្តម អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចូលរួមជាកិត្តិយសក្នុងពិធីបិទសិក្ខាសាលាស្តីពី “ វិធីសាស្ត្រតាក់តែងសេចក្តី សម្រេចតុលាការ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ។

- បានទទួលលិខិតលេខ ០១៣/ក.យ/០៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ពីក្រសួងយុត្តិធម៌ នូវរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ឯកឧត្តម ប្រតិភូដឹកនាំសហការីក្នុងនាមតំណាងជូសមុខ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចុះស្វែងយល់ និងស្ទង់នូវមតិ នូវចំណោះ

ដឹងមន្ត្រីកំពុងអនុវត្តច្បាប់ ដែលបានទទួលវគ្គអប់រំបណ្តុះបណ្តាល ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី។

- បានទទួលលិខិត របស់ UNDP ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពី International Coordinator-Access to Justice Project(Ms. Dorin Van Der Keur will take on the function of International Coordinator of the A2J Project from August 1,

- បានទទួលលិខិត របស់ UNDP ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពី Invitation to attend the United Nations Development Assistance Framwork (UNDAF) 2011-2015 Strategic Workshop, Siem Reap10-12 August 2009 ។

- បានទទួលប្រកាសលេខ ១២៥ ប្រក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី នូវប្រកាសស្តីពី ការតែងតាំងសិស្សក្រឡាបញ្ជី ជំនាន់ទី២ នៃរាជបណ្ឌិតសភាវិជ្ជជីវៈតុលាការ ។

- បានទទួលលិខិតលេខ ០៥៤/០៩ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សំណើអញ្ជើញ ឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចូលរួមប្រជុំ ដើម្បីពិភាក្សាលើការរៀបចំចងក្រងផែនការសកម្មភាព អភិបាល-កិច្ចទី៣ ការបន្តចងក្រងកម្រងព័ត៌មានសេវាសាធារណៈ និងការពង្រឹងការគ្រប់គ្រងចំណាយថវិកាលើបៀវត្ស និងប្រាក់បំណាច់ផ្សេងៗ។

- បានទទួលលិខិតលេខ ៩៣៣/គ.ម/០៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ ពីគណៈមេធាវីកម្ពុជា ស្តីពីការដាក់សំណូមពរ ឬញ្ញាត្តិនៅពេលមហាសន្និបាតរបស់គណៈមេធាវី លើកទី១៥។

- ទទួលប្រកាសលេខ ១២៧ ប្រក.បល ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី នូវប្រកាសស្តីពីការអនុញ្ញាតិឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ។

- បានទទួលលិខិតលេខ ៩៩៦/០៩ របវត/អ.គ.ដ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ ពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការស្តីពីសំណើសុំអញ្ជើញចៅក្រម និងព្រះរាជអាជ្ញា ចូលរួមវគ្គបណ្តុះបណ្តាលបន្តស្តីពី “ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ភូមិបាល ” ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៧-២១ ខែសីហា ឆ្នាំ២០០៩ នៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជជីវៈតុលាការ ។

-បានទទួលលិខិត ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេស ជប៉ុន(Japan International Agency)ស្តីពីការទទួលស្គាល់របស់ទីភ្នាក់ងារ សហប្រតិ-បត្តិការអន្តរជាតិនៃប្រទេស ជប៉ុន ស្តីពីការផ្តល់អាហារូបករណ៍រយៈពេលវែង សម្រាប់ថ្នាក់អនុបណ្ឌិត និង ថ្នាក់បណ្ឌិតនៅប្រទេសជប៉ុន សម្រាប់ឆ្នាំសិក្សា២០០៩9 (Acceptance of the Nominee on JICA Long-Term Training Program (Masters or Doctors Degree)for fiscal year 2009

- បានទទួលលិខិតលេខ ៣៩៥ លអជ.រប ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមត្រួតពិនិត្យ ចម្រុះលើបទល្មើសចរាចរណ៍ផ្លូវគោក ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃពុធ-ព្រហស្បតិ៍ ទី១២-១៣ វេលាម៉ោង ៨ះ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី (ជាន់ទី៣ សាលD)។

- បានទទួលលិខិតលេខ ៣៩៦ លអជ.រប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវព័ត៌មានវិទ្យាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តី

ការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃ២០ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ ។

- បានទទួលសេចក្តីសម្រេច លេខ ៨០ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី នូវសេចក្តីសម្រេចស្តីពីការបែងចែកប៉ុស្តិ៍សិស្សក្រឡាបញ្ជី ជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការអោយទៅបម្រើការងារនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូង រាជធានី-ខេត្ត។

- បានទទួលលិខិតលេខ ០៥៧/០៩ លអជ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីសំណើអញ្ជើញតំណាងចូលរួមប្រជុំដើម្បីពិភាក្សាបន្តលើការបំពេញព័ត៌មានទៅក្នុងទម្រង់ “ផែនការ កែលម្អការផ្តល់សេវាសាធារណៈ ” នៃផែនការសកម្ម-ភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣ )(ផ.ស.អ ទី៣ )។

- បានទទួលលិខិតលេខ ១២១៤ លស.បល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើបំពេញព្រឹត្តប័ត្រកំណត់ពិន្ទុវិជ្ជាជីវៈមន្ត្រីរាជការ ដែលត្រូវតម្លើងថ្នាក់បៀវត្សប្រចាំឆ្នាំ២០១០ ។

- បានទទួលលិខិតលេខ ១២១៥ លស.បល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើធ្វើលិខិតស្នើសុំសម្រាប់មន្ត្រីជាប់កិច្ចសន្យាប្រចាំឆ្នាំ២០១០។

- បានទទួលលិខិតលេខ ១២១៦ លស.បល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពី ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើបញ្ជូនឈ្មោះមន្ត្រីរាជការ ដែលត្រូវទទួលគ្រឿងឥស្សរិយយស សម្រាប់-ឆ្នាំ២០០៩។

- បានទទួលលិខិតលេខ ១២១៧ លស.បល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើធ្វើលិខិតបញ្ជាក់ការសិក្សាកូនប្រចាំឆ្នាំ២០១០។

- បានទទួលលិខិតលេខ ១៨ ដនស/អរប/រប ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវរបាយការណ៍ បូកសរុបលទ្ធផលអនុវត្តការងារឆមាសទី១ ឆ្នាំ២០០៩ និងទិសដៅបន្ត។

- បានទទួលលិខិតលេខ ៤០៦ មហក/០៩ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ពីមហាអយ្យការអមសាលាឧទ្ធរណ៍ ស្តីពីការបញ្ជូនបញ្ជីស្ថិតិពិរុទ្ធជន ឃុំខ្លួនហួសនីតិវិធី នូវបញ្ជីឈ្មោះពិរុទ្ធជនគ្រប់ខេត្ត-រាជធានី។

- បានទទួលលិខិតលេខ ៣៥២ លអជ.រប ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីបិទសិក្ខាសាលាស្តីពី “ការខិតខំប្រឹងប្រែងផ្នែកសន្តិសុខក្នុងការប្រឆាំងភេរវកម្ម នៅអាស៊ីអាគ្នេយ៍ ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ១០ៈ០០នាទី នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ។

-បានទទួលលិខិតលេខ ០១៣/០៩ ក.ហ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ពីអគ្គលេខធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នូវកំណត់ហេតុស្តីពីលទ្ធផល នៃកិច្ចប្រជុំអន្តរក្រសួង ។

- បានទទួលលិខិតលេខ ៣៨៩ លអជ.រប ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូររួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីទិវាជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ និងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីក្រមសីលធម៌ទន្តពេទ្យ ដែលនឹង

ប្រព្រឹត្តទៅ នៅថ្ងៃអង្គារ៍ទី១៨ ខែសីហា ឆ្នាំ២០០៩ និងនៅថ្ងៃព្រហស្បត៍ទី២០ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី ។

- បានទទួលលិខិតលេខ ៣៥០ លអជ.រប ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំ អន្តរក្រសួងចង្អៀត ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃសាលាឧទ្ធរណ៍ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធទី១៩ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង០៨០ៈ៣០ នាទីនៅ ទីស្តីការគណៈរដ្ឋមន្ត្រី ។

- បានទទួលលិខិតឧទ្ទេសនាម លេខ៥២៧ ឧ.ទ.ន ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៩ ត្រូវបានអនុញ្ញាតឱ្យ កញ្ញា ផាន ពិសីនលក្ខណ៍ ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកច្បាប់ពាណិជ្ជកម្ម និង សេដ្ឋកិច្ចអន្តរជាតិនៅ ប្រទេសជប៉ុន ចាប់ពីខែកញ្ញា ឆ្នាំ២០០៩ រហូតដល់ ខែកញ្ញា ឆ្នាំ២០១០ ដោយរក្សាក្របខ័ណ្ឌ និងប្រាក់បៀវត្ស ជូនសាមីខ្លួនរហូតដល់បញ្ចប់ការសិក្សា វិលត្រឡប់មកមាតុភូមិវិញ។

- បានទទួលលិខិតលេខ ១១០៧. សជណ.ជហ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសេចក្តីជូនដំណឹងផ្សេងៗ ៖ ១- ក្នុងចន្លោះថ្ងៃទី២០ ដល់ថ្ងៃទី៣០ សីហា ឆ្នាំ២០០៩ អ្នកបច្ចេកទេសជណ្តើរយន្តភាគីចិននឹងចាប់ផ្តើមធ្វើការជួសជុល អោយមានការល្អប្រសើរដូចធម្មតាវិញ ។

-បានទទួលលិខិតលេខ ៥៩៥/គ.ម/០៩ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ពីគណៈមេធាវី ស្តីពីការផ្តល់ នូវអាស័យដ្ឋានអ៊ីម៉ែល របស់គណៈមេធាវី និងអ៊ីម៉ែលរបស់ថ្នាក់ដឹកនាំគណៈមេធាវី ព្រមទាំងនាយកដ្ឋាន គណៈកម្មការផ្សេងៗ និងបុគ្គលិកទាំងអស់របស់គណៈមេធាវី ។

-បានទទួលលិខិតចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០០៩ ពីអង្គការសហប្រជាតិប្រចាំនៅកម្ពុជា ស្តីពីការអញ្ជើញចូលរួមសិក្ខាសាលាសីពី ៖ (UNDAF) 2011-2015 Strategic Workshop, Siem Reap10-12 August Cambodia

-បានទទួលលិខិតលេខ ៦០៩/គ.ម/០៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ពីគណៈមេធាវីកម្ពុជា ស្តីពីការជ្រើសរើសគណៈកម្មការរៀបចំការបោះ ឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៦ (២០០៩-២០១១២ ) និងអ្នកចាត់តាំងកម្មវិធីក្នុងការបោះឆ្នោត

-បានទទួលលិខិតលេខ ១១៨៨/០៩ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ពីក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ស្តីពីសំណើអញ្ជើញចូលរួមសិក្ខាសាលាស្តីពីការពង្រឹងប្រសិទ្ធិភាពនៃភាពជាដៃគូដែលរៀបចំឡើងនៅថ្ងៃទី ០៩-១០ ខែកញ្ញា ឆ្នាំ២០០៩ នៅសណ្ឋាគារ Angkor Century ខេត្តសៀមរាប។

- បានទទួលរបាយការណ៍លេខ ១០ជ/០៩ របក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ពីអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាកំណែទម្រង់ រដ្ឋបាល នូវរបាយការណ៍ស្តីពីកិច្ចប្រជុំអន្តរក្រសួងដើម្បីរៀបចំចងក្រងផែនការ សកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣ )។

-បានទទួលលិខិតពី UNDP ពីចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០៩ ស្តីពី Revised Agenda for Board Meeting and Quarterly Progress Report on 25 August 2009។

-បានទទួលលិខិតលេខ ៣៦០ លអជ.រប ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រីអញ្ជើញ ឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងសហការី ចំនួន០៣ រូប ចូលរួមក្នុងអង្គប្រជុំផ្ទៃក្នុង ដើម្បីពិភាក្សាលើករណីនៃការកសាងលិខិតបទដ្ឋានគតិយុត្តិ របស់ក្រសួង-ស្ថាប័ន ក្នុងរយៈពេលកន្លងមក និងរយៈពេល ០៥ឆ្នាំ របស់

រាជរដ្ឋាភិបាលក្នុងអាណត្តិទី៤ នៃរដ្ឋសភា ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី ។

- បានទទួលលិខិតលេខ ៣៦១ លអជ.រប ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាបន្តលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីក្រមសីលធម៌ទន្តពេទ្យ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ-ព្រហស្បតិ៍ទី២៦-២៧ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០នាទីព្រឹក។

- បានទទួលលិខិតលេខ ១៩៤/០៩ លស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ពីអគ្គលេខាធិការដ្ឋានក្រុម ប្រឹក្សាកំណែទម្រង់រដ្ឋបាល សំណើរសុំផ្តល់ឯកសារផែនការ សកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣)។

- បានទទួលលិខិតលេខ ៣៨៧ លអជ.រប ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបោះពុម្ពសារ ព្រមានសុខភាពលើកញ្ចប់បារី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ៍ទី០១ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ នាទី ។

- បានទទួលលិខិតលេខ ៥៥៦/០៩/របរត/អគជ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ពីសាលារាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ស្តីពីការអញ្ជើញថៅក្រម និងព្រះរាជអាជ្ញា ចូលរួមវគ្គបណ្តុះបណ្តាលបន្ត "សេចក្តីព្រាង ក្រមព្រហ្មទណ្ឌ-ក្រមនីតិវិធីព្រហ្មទណ្ឌ និង ច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើ អាជីវកម្មផ្លូវភេទ " ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៤-២៧ ខែសីហា ឆ្នាំ២០០៩ មានចំនួន ៣៤ ច្បាប់។ ថ្ងៃទី៣១ ខែសីហា នឹង ០១-០៤ ខែកញ្ញា ឆ្នាំ២០០៩ មានចំនួន៣៥ ច្បាប់ នឹងនៅថ្ងៃទី ០៧-១១ ខែកញ្ញា ឆ្នាំ២០០៩ ចំនួន ៣៤ ច្បាប់។

- បានទទួលលិខិតលេខ ៣៦៨ លអជ.រប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យឆ្លងពុទ្ធាពិសេកព្រះពុទ្ធរូបអង្គធំ និងសមិទ្ធិផលនានានៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០៧ៈ៣០ នាទី ។

- បានទទួលលិខិតលេខ ៣៨៧ លអជ.រប ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ-ព្រហស្បតិ៍ទី២-៣ ខែកញ្ញាឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី។

- បានទទួលលិខិតពី Australian Government (AusAID) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ស្តីពីថវិការសម្រាប់តុលាការគំរូ(Model Court Funding) ។

- បានទទួលលិខិតលេខ ៣៨១ លអជ.រប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីដង្ហែរត្រៃបិដក និងក្រុងពាលីបុណ្យឆ្លងពុទ្ធាពិសេកព្រះពុទ្ធរូបអង្គធំ និង សមិទ្ធិផលនានានៅភ្នំជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៣ៈ៣០ នាទី។

**ខ.ការងារកំណែទម្រង់**

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- បានរៀបចំកិច្ចប្រជុំ ដើម្បីដោះស្រាយបញ្ហាប្រឈមកក្នុងវិស័យតុលាការ ដោយមានការអញ្ជើញចូលរួម ពីស្ថាប័នដែលពាក់ព័ន្ធនិងវិស័យចូលរួម និងស្ថាប័នពាក់ព័ន្ធមួយចំនួន ដូចជាក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។

- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ក្រោមអធិបតីភាពឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរងដោយផ្តោត ទៅលើការបន្តការពិភាក្សាធ្វើផែនការយុទ្ធសាស្ត្រ របស់អគ្គលេខា-ធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលបានរៀបចំសិក្ខាសាលារយៈពេលបីថ្ងៃនៅទីរួមខេត្តកោះកុង ។ ការពិភាក្សាដោយផ្អែកទៅលើលទ្ធផលដែល បានធ្វើនៅខេត្តកោះកុង ដោយគ្រាន់តែកែតម្រូវបន្ថែមឃ្លាឃ្លោង និងអក្ខរាវិរុទ្ធ ប៉ុណ្ណោះ។

- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា នៅថ្ងៃអង្គារ៍ ទី២៥ ខែសីហា ឆ្នាំ ២០០៩ វេលាម៉ោង២ៈ៣០ នាទី នៅសណ្ឋាគារ អ៊ីមភើរៀ ។ កិច្ចប្រជុំក្រុមប្រឹក្សាគម្រោងនេះគឺដើម្បីបង្ហាញពី ការរីកចម្រើនសមិទ្ធិផលនៃការអនុវត្តគម្រោងក្នុងត្រីមាសទី ១ និងត្រីមាសទី២ នៃឆ្នាំ២០០៩ បញ្ហាប្រឈមខ្លះក្នុងការអនុវត្តគម្រោង និងអំពីសំណើកែតម្រូវលើផែន-ការថវិកា ដែលមានការផ្លាស់ប្តូរខ្លះៗ ដែលបង្ហាញដោយ លោកស្រី Dorine Van Der Koeur ហើយត្រូវបានក្រុមប្រឹក្សាគម្រោង អនុម័តយល់ព្រមនូវ បទបង្ហាញអំពី សមិទ្ធិផលចំពោះត្រីមាសទី១ និងត្រីមឆាស់ទី២ នៃឆ្នាំ២០០៩ និងបានកំណត់យក ខែវិច្ឆកា ឆ្នាំ២០០៩ សម្រាប់ ការប្រជុំលើកក្រោយទៀត។

- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង កាលពី ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ក្រោមអធិបតីភាពរបស់ ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ ដើម្បីពីភាក្សា ទៅលើប្រធានបទ “តុលាការរដ្ឋបាល ”ព្រមទាំងបានរៀបចំក្រុមការងារដើម្បីធ្វើពង្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើត តុលាការរដ្ឋបាល។

- ក្រុមគម្រោងនីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំ និងធ្វើផែនការការងារសម្រាប់ឆ្នាំ២០០៩។

**គ. ផ្សេងៗ**

- ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងផ្សេងៗ

- ចូលរួមក្នុងកិច្ចប្រជុំ ជាមួយគណៈប្រតិភូធនាគាពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើៈ ប្រធានបទពាក់ព័ន្ធនិង អភិបាលកិច្ចល្អ សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ និង Land Mapping ។

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៩ៈ០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យវឌ្ឍនភាពនៃប្រព័ន្ធក្រុមការងារបច្ចេកទេសចម្រុះ កាលពីថ្ងៃទី១៣-១៤ ខែសីហា ឆ្នាំ២០០៩ នៅសណ្ឋាគាអប្សរាអង្គរ ខេត្តសៀមរាប ដែលរៀបចំ

ឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានក្រុមការបច្ចេកទេសនៅតាមក្រសួងស្ថាប័នទាំង ១៨ ក្រុមចូលរួម ដោយផ្តោតទៅលើ -ការពិនិត្យមើលទៅលើវឌ្ឍនភាពនៃសូចនាករទាំងឡាយ -កាតព្វកិច្ចរបស់ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ស្តីពីរបាយការណ៍ TWG -របាយការណ៍ជាធម្មតា ជាទម្លាប់របស់ក្រុមការងារនិមួយៗ រាយការណ៍ជូនទៅ GDCC ដើម្បីធ្វើការបូកសរុប។

## ២-សន្និដ្ឋាន

-ក្នុងខែសីហា ឆ្នាំ២០០៩ នេះអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាមួយស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ និងបានរៀបចំកិច្ចប្រជុំ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យតុលាការ ដោយមានការអញ្ជើញចូលរួមពីស្ថាប័នដែលពាក់ព័ន្ធនិងវិស័យចូលរួម និងស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជាក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ។

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏បានខិតខំបន្តការរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដោយផ្តោតជាសំខាន់ទៅលើការការរៀបចំផែនការយុទ្ធ -សាស្ត្ររបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចំនួនពីរលើក គឺលើកទី១ បានរៀបចំឡើងនៅថ្ងៃទី១៥-១៧ខែកក្កដា ឆ្នាំ២០០៩ នៅទីរួមខេត្តកោះកុង មានរយៈពេលពីរថ្ងៃ និងបានបន្តរធ្វើលើកទីពីរនៅខេត្តព្រះសីហនុ រយៈពេល ១ថ្ងៃកន្លះ ជាលទ្ធផលក្រុមការងារដែលបានបញ្ចប់នូវផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាស្ពានរនូវសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនេះ ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

- បន្តតាមដានការអនុវត្តគម្រោងតុលាការគំរូ
- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន
- បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពីមុខងារស្ថាប័នរដ្ឋ

-ត្រៀមរៀបចំសន្និសិទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨

-ត្រៀមបញ្ជូនមន្ត្រី ១រូប នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីទៅសិក្សាថ្នាក់អនុបណ្ឌិតផ្នែកច្បាប់ពាណិជ្ជកម្ម និងសេដ្ឋកិច្ចអន្តរជាតិនៅទីក្រុងហ្វូគុយកា-កិន (Fukuokaken) ប្រទេសជប៉ុន។

-ត្រៀមរៀមចំសិក្ខាសាលាស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរយោបល់ជាមួយទីភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅតាមបណ្តាខេត្តចំនួនបួនៈ ខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ធំ និងខេត្តព្រៃវែង នៅក្នុងខែកញ្ញាខាងមុខ។

*រាជធានី ភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩*

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**